អង្គការអនុផលព្រៃឈើ
Non-Timber Forest Products

# ក្រមសីលធម៌នៃគោលនយោបាយការការពារកុមារ

អង្គការអនុផលព្រៃឈើ(NTFP)ប្តេជ្ញាធានាថាកុមារដែលយើងធ្វើការជាមួយនិងដើម្បីមានសុវត្ថិភាពពីការរំលោភបំពាននានា។

<u>គោលការណ៍ជារួម</u>

បុគ្គលិកអង្គការNTFPនិងអ្នកចូលរួមសកម្មភាពជាមួយអង្គការNTFPត្រូវអង្កេតយ៉ាងហ្មត់ចត់លើអាកប្បកិរិយាសមរម្យ ដូចជា:

- ស្វែងយល់ពីអត្ថន័យនៃការរំលោភបំពានឬកេងប្រវ័ញ្ចលើកុមារនិងគោលនយោបាយការពារកុមារនិងក្រមសីលធម៌។
- យល់ដឹងពីសញ្ញាណនៃការរំលោភបំពាននិងរាយការករណីសង្ស័យជាបន្ទាន់ដល់ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារឬអ្នករៀបចំសកម្មភាព
- គោរពនូវយន្តការរាយការណ៍ដែលបានណែនាំ
- គោរពនូវសិទ្ធិនិងភាពថ្លៃថ្នូររបស់កុមារ ព្រមទាងច្បាប់ជាតិនិងអន្តរជាតិ
- ធានាថាកុមារដែលចូលរួមទាំងអស់ទទួលបានការគោរពនៅកម្រិតខ្ពស់បំផុតពីអ្នកចូលរួមផ្សេងទៀត
- ការពារខ្លួនឯងនិងអ្នកដទៃទាំងសុខភាពសុវត្ថិភាពនិងសុខមាលភាពព្រមទាំងរក្សានូវក្រមសីលធម៌វិជ្ជាជីវៈនិងជាបុគ្គល

ដើម្បីការពារកុមារដែលចូលរួមសកម្មភាពជាមួយអង្គការNTFPបុគ្គលិកអង្គការNTFPនិងអ្នកចូលរួមសកម្មភាពជាមួយអង្គការNTFPទាំងអស់មានកាតព្វកិច្ចដូចខាងក្រោម:

1. មិនត្រូវចូលរួមក្នុងសកម្មភាពផ្លូវភេទជាមួយកុមារជាអ្នកចូលរួម
2. មិនត្រូវស្ទាបអង្អែល ថើប ឱបរឹត ឬការប៉ះពាល់មិនសមរម្យផ្សេងទៀតចំពោះកុមារ
3. ធានាថាកុមារដែលចូលរួមទាំងអស់មិននៅក្រៅបន្ទប់សម្រាកឬដដែកជាមួយអ្នកដទៃនៅក្រោមម៉ោង១០យប់
4. ចៀសវាងនូវឥរិយាបទឬសកម្មភាពដែលអាចបង្កជាការរំលោភបំពានឬអារម្មណ៍ផ្លូវភេទលើកុមារ
5. គិតពិចារណាពីការផ្តល់យោបល់និងឥរិយាបទក្នុងការនិយាយ អនុវត្តសកម្មភាព និងទំនាក់ទំនងជាមួយកុមារនិងយុវវ័យ

6. រក្សាភាពសំងាត់ពីព័ត៌មានបុគ្គលរបស់កុមារអ្នកចូលរួម
7. មិនស្នាក់នៅលើគ្រែតែមួយជាមួយកុមារឬនៅកន្លែងស្ងាត់តែពីរនាក់ជាមួយកុមារ
8. មិនត្រូវធ្វើការងារជំនួសកុមារនៅពេលដែលពួកគេអាចធ្វើបានដោយខ្លួនឯង
9. មិនរើសអើង ធ្វើឲ្យអាម៉ាស់ បន្ទោសបង្អាក់ បន្ទាបបន្ថោក មើលងាយចំពោះកុមារ
10. មិនត្រូវវាយដំ ជេរប្រមាថ ទាត់ធាក់ចំពោះកុមារ
11. មិនត្រូវបង្កសកម្មភាពដែលជាទម្រង់រំលោភបំពាន ឬផ្តល់ហានីភ័យនៃការរំលោភបំពាន
12. មិនត្រូវឲ្យកុមារនៅកន្លែងដែលអាចប៉ះពាល់ដល់គ្រឿងញៀន គ្រឿងស្រវឹង បារី និងសម្ភារៈអគ្គីសនីដែលមានភាពគ្រោះថ្នាក់ ព្រមទាំងទទួលនូវព័ត៌មានបែបអាសអាភាស
13. មិនត្រូវមើលស្រាលឬបំផ្លើសបំប៉ោងបញ្ហារំលោភបំពានកុមារឡើយ
14. មិនត្រូវជឿថា″រឿងនេះមិនអាចកើតមានចំពោះអាត្មាខ្លួននោះឡើយ″
15. មិនត្រូវរំលោភបំពានលើក្រមសីលធម៌ខាងលើទាំងបុគ្គលិកនិងអ្នកចូលរួម
16. នៅពេលជួបករណីសង្ស័យនៃការរំលោភបំពានលើកុមារ ត្រូវរាយការណ៍ដល់ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារសម្រាប់សកម្មភាពនោះ ឬទៅអ្នករៀបចំ ឬទៅអជ្ញាធរមានសមត្ថកិច្ចដែលនៅជិតឬទុកចិត្តបាន។

បុគ្គលិកអង្គការNTFPត្រូវធ្វើការណែនាំគោលនយោបាយកិច្ចការពារកុមារ និងក្រមសីលធម៌នេះដល់អ្នកចូលរួមទាំងអស់ និងកុមារនៅគ្រប់ពេលអនុវត្តសកម្មភាពជាមួយកុមារ។

ខ្ញុំបានអានគោលនយោបាយ នីតិវិធី និង ក្រមសីលធម៌ខាងលើ ស្តីពីការការពារកុមារ និងយល់ខ្លឹមសារទាំងស្រុង។ ខ្ញុំឯកភាព និងព្រមអនុវត្តតាម គោលនយោបាយ និង ក្រមសីលធម៌ខាងលើនេះទាំងស្រុង។

ចុះហត្ថលេខាដោយ:..........................................

តួនាទី:...............................................................

កាលបរិច្ឆេទ:.....................................................